# ព្រះរាជាណាចក្រកម្ពុជា

ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់ អូតែល-កូបេ **ជាតិ សាសនា ព្រះមហាក្សត្រ**

LE PRESIDENT HOTEL-KOBE

## កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១៥ថ្ងៃ គឺចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

ថ្ងៃចន្ទ ទី៦កើត ខែភទ្របទ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវ និងថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០ វេលាម៉ោងប្រាំបួនព្រឹក មានកិច្ចប្រជុំមួយនៅ ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់ អូតែល-កូបេ មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ៦៨០ ផ្លូវកម្ពុជាក្រោម សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ដែលមានចំនួនកម្មករនិយោជិតសរុប ចំនួន២២៣នាក់ កម្មករនិយោជិតជាស្ត្រីមានចំនួន១៣៨នាក់ មាននាយកឈ្មោះ គឹម វិបុល ជនជាតិខ្មែរ ជាតំណាងក្រុមហ៊ុនឡឺ ប្រេស៊ីដង់ អូតែល-កូបេ បានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករ និយោជិតរយៈពេល១៥ថ្ងៃ។

ជាកិច្ចចាប់ផ្តើមលោក គឹម វិបុល ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំក្នុងថ្ងៃនេះ បន្ទាប់មកលោកប្រធានអង្គប្រជុំមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់មូលហេតុដោយសារតែបញ្ហាការផ្ទុះមេរោគឆ្លងជាសាកល កូវីដ-១៩ ធ្វើអោយភ្ញៀវមានការធ្លាក់ចុះយ៉ាងខ្លាំង ដូចនេះក្រុមហ៊ុន ឡឺ ប្រេស៊ីដង់អូតែល-កូបេ និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ២០នាក់រយៈ១៥ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០ ដល់ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០។

២-ក្នុងអំឡុងនៃការព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតនិងទទួលបានប្រាក់ឧបត្ថម្ភ៣០ដុល្លារក្នុង ១៥ថ្ងៃ ។

ភ្នំពេញថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០

បានឃើញ និងឯកភាព

តំណាងក្រុមហ៊ុន

តំណាងកម្មករនិយោជិត